# ក្រសួងមុខងារសាធារណៈ

# លទ្ធផលការងារ

## បញ្ហាប្រឈម និងទិសដៅការងារបន្ត
## មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត

## ឯកឧត្តម ជុក មុន្នី អនុរដ្ឋលេខាធិការ
## ក្រសួងមុខងារសាធារណៈ

# មាតិកា

១. សេចក្តីផ្តើម

២. លទ្ធផលការងារ

៣. បញ្ហាប្រឈម

៤. ទិសដៅការងារបន្ត

# ១. សេចក្តីផ្តើម

- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវបានបង្កើតឡើងតាមរយៈប្រកាសលេខ១៩៧៩មស.នក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មានការិយាល័យជំនាញចំនួន៣ត្រូវបានបង្កើតឡើងគឺ
  - (១)ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ
  - (២)ការិយាល័យក្របខណ្ឌនិងបណ្តុះបណ្តាល
  - (៣)ការិយាល័យត្រួតពិនិត្យរដ្ឋបាលនិងបៀវត្ស។

ឧបសម្ព័ន្ធនៃប្រកាសលេខ ១៤៩ ៣៤៩ សហ.ប្រក
ចុះថ្ងៃទី ១៩ នៃ ខែធ្នូ ឆ្នាំ២០១៤

## អង្គការលេខរបស់មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត



# ២. លទ្ធផលការងារ

**ក្នុងរយៈពេល៥ឆ្នាំនៃការអនុវត្តការងាររបស់ខ្លួន មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត សម្រេចបានលទ្ធផលដូចខាងក្រោម៖**

- (១) ពិនិត្យ និងផ្តល់ទិដ្ឋាការប្រែប្រួលស្ថានភាពរដ្ឋបាលមន្ត្រីរាជការតាមមន្ទីរ អង្គភាពនានា ជុំវិញរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានទាន់ពេលវេលា និងមានប្រសិទ្ធភាព
- (២) ធ្វើនិយ័តកម្មថ្នាក់ ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការនៅតាមបណ្តាមន្ទីរ និងអង្គភាពនានាជុំវិញខេត្ត ក្រុង ស្រុក ខណ្ឌ
- (៣) អនុវត្តតួនាទីសេនាធិការជូនគណៈអភិបាល រាជធានី ខេត្ត ក្នុងការផ្តល់យោបល់លើការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ដូចជាការវិភាគមុខតំណែងដែលត្រូវតែងតាំង ការលើកផែនការនិងការជ្រើសរើសមន្ត្រីរាជការ ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលជាដើម ឱ្យត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន

- (៤) ចូលរួមជាតំណាងក្រសួងមុខងារសាធារណៈនៅក្នុងគណៈកម្មការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិល នៅតាមរាជធានី ខេត្ត
- (៥) ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើតារាងបៀវត្សរបស់ មន្ទីរ អង្គភាពនានាជុំវិញរាជធានី ខេត្ត បានទាន់ពេលវេលា និងមានប្រសិទ្ធភាព
- (៦) ចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យការប្រើប្រាស់គ្រូបង្រៀនពីរវេន ថ្នាក់គួបគ្រូជាប់កិច្ចសន្យា និងមន្ត្រីជាប់កិច្ចសន្យារបស់មន្ទីរអប់រំ យុវជន និងកីឡា នៅទូទាំង២៥រាជធានី ខេត្ត
- (៧) រៀបចំវគ្គបណ្តុះបណ្តាល និងសម្របសម្រួលការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា ដែលដាក់ចេញឱ្យអនុវត្តដោយក្រសួង ស្ថាប័ននានា និងរាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យមុខងារសាធារណ
  - ថ្នាក់ក្រសួង៖ ឆ្នាំ២០១៦ សរុបចំនួន **៣៦៦៩** នាក់ (ស្រី១១២៤ នាក់)
    ឆ្នាំ២០១៧ សរុបចំនួន **៣២៩៦** នាក់ (ស្រី១១៣១ នាក់)
  - ថ្នាក់មន្ទីរ៖ ចំនួនផ្សព្វផ្សាយ **១៧៩លើក** អ្នកចូលរួមសរុប **២៤៦៨២** (ស្រី**៦៦៥២**នាក់)

## ការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

| ល.រ | មន្ទីរមុខងារសាធារណៈខេត្ត | ថ្នាក់ក្រសួង | | | | ថ្នាក់មន្ទីរ | | |
|---|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៦ | | ឆ្នាំ២០១៧ | | ចំនួនផ្សព្វផ្សាយ | សរុប | ស្រី |
| | | សរុប | ស្រី | សរុប | ស្រី | | | |
| 1 | កំពង់ឆ្នាំង | 174 | 60 | 198 | 86 | 5 | 868 | 346 |
| 2 | កំពង់ស្ពឺ | 175 | 38 | 184 | 48 | 32 | 7559 | 1700 |
| 3 | ស្វាយរៀង | 202 | 36 | 588 | 170 | 6 | 494 | 102 |
| 4 | ត្បូងឃ្មុំ | | | 200 | 80 | 1 | 40 | 20 |
| 5 | ស្ទឹងត្រែង | 136 | 75 | 190 | 60 | 3 | 570 | 221 |
| 6 | រតនគិរី | 160 | 29 | 245 | 28 | 9 | 315 | 54 |
| 7 | មណ្ឌលគិរី | 114 | 30 | 150 | 54 | 8 | 258 | 96 |
| 8 | ក្រចេះ | 110 | 25 | 380 | 175 | 4 | 615 | 240 |
| 9 | ឧត្តរមានជ័យ | | | 131 | 37 | 1 | 74 | 21 |
| 10 | បន្ទាយមានជ័យ | 198 | 78 | 198 | 87 | 9 | 777 | 287 |
| 11 | ពោធិ៍សាត់ | 97 | 26 | 242 | 87 | 12 | 540 | 162 |
| 12 | កណ្តាល | | | 200 | 85 | | | |
| 13 | កំពង់ធំ | 437 | 75 | 180 | 94 | 9 | 342 | 84 |
| 14 | កោះកុង | 140 | 53 | | | | | |
| 15 | ភ្នំពេញ | 310 | 110 | | | | | |
| 16 | កំពង់ចាម | | | | | 9 | 2000 | 800 |
| 17 | សៀមរាប | | | | | 6 | 4215 | 1324 |
| 18 | ព្រះសីហនុ | 368 | 171 | | | 11 | 1987 | 512 |
| 19 | កែប | 178 | 58 | 111 | 20 | 2 | 85 | 21 |
| 20 | តាកែវ | | | | | 18 | 1085 | 338 |
| 21 | ព្រះវិហារ | 198 | 86 | | | 4 | 373 | 146 |
| 22 | បាត់ដំបង | 150 | 61 | | | 7 | 514 | 125 |
| 23 | ប៉ៃលិន | 64 | 9 | 99 | 20 | 5 | 347 | 60 |
| 24 | កំពត | 216 | 60 | | | 7 | 1011 | 198 |
| 25 | ព្រៃវែង | 242 | 44 | | | 11 | 613 | 133 |
| សរុបរួម | | 3669 | 1124 | 3296 | 1131 | 179 | 24682 | 6652 |

- (៨) ចុះពិនិត្យលើការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាមិនប្រក្រតីរបស់មន្ទីរ អង្គភាពនានា
- (៩)បានអនុវត្តជំហានសាកល្បងនៅខេត្តកំពង់ស្ពឺ លើការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបញ្ចូលទិន្នន័យ (drag and drop system) បញ្ចូលតារាងបៀវត្ស និងឯកសារពាក់ព័ន្ធផ្សេងៗទៀត តាមប្រព័ន្ធអេឡិចត្រូនិច។
- (១០) បង្វែរថវិការបស់មន្ទីរ អង្គភាពនានាជុំវិញខេត្ត ចូលថវិកាជាតិវិញ
- (១១) អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួង និងរាជរដ្ឋាភិបាលប្រគល់ជូន ជាពិសេស ពាក់ព័ន្ធទៅនឹងការងារកែទម្រង់ស៊ីជម្រៅ ជាអាទិ៍៖ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ល។

# ៣. បញ្ហាប្រឈម

ក្នុងការអនុវត្តការងារ មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា៖

- (១) បញ្ហាប្រឈមផ្នែកធនធានមនុស្ស

ដោយសារមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ទើបបង្កើតថ្មី មន្ត្រីរាជការបម្រើការងារនៅក្នុងមន្ទីរមានសមាសភាពចំរុះមកពីគ្រប់មន្ទីរអង្គភាពនានា ព្រមទាំងសមត្ថភាពនៅមានកម្រិត ដែលត្រូវការការបណ្តុះបណ្តាលជាចាំបាច់។

- (២) បរិយាកាសការងារ មិនទាន់សមស្រប ដោយសារពុំទាន់មានអគាររដ្ឋបាលដាក់លាក់សម្រាប់បំពេញការងារ
- (៣) នៅមានការខ្វះមធ្យោបាយអនុវត្តការងារដូចជា សម្ភារប្រើប្រាស់ក្នុងការិយាល័យ ម៉ូតូ និងរថយន្ត ដែលបង្កជាការលំបាក ក្នុងការបំពេញបេសកកម្មនៅតំបន់ឆ្ងាយៗ

# ៤. ទិសដៅការងារបន្ត

ក្នុងគោលដៅបង្កើនប្រសិទ្ធភាពការងារ និងការគ្រប់គ្រងវិស័យមុខងារសាធារណៈនៅថ្នាក់ក្រោមជាតិ នៅក្នុងផែនការសកម្មភាពឆ្នាំ ២០១៨ របស់ខ្លួន មន្ទីរមុខងារសាធារណៈបានដាក់ចេញទិសដៅអនុវត្តការងារមានជាអាទិ៍៖

- (១) បន្តពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យរដ្ឋបាល និងបៀវត្ស
- (២) បន្តពង្រឹងប្រសិទ្ធភាពនៃការកសាងផែនការធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ការងារគ្រប់គ្រងក្របខណ្ឌ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែត
- (៣) ជម្រុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យានៅក្នុងការអនុវត្តការងារ

- (៤) ជម្រុញនិងអនុវត្តការលើកកម្ពស់គុណផល និងការទទួលខុសត្រូវរបស់មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ
- (៥)បន្តពង្រឹងការគ្រប់គ្រងការប្រើប្រាស់ និងការបើកផ្តល់ប្រាក់លាភការដល់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត
- (៦) ជម្រុញនិងអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈនៅថ្នាក់ក្រោមជាតិ
- (៧) ពង្រឹងនិងពង្រីក ការអភិវឌ្ឍស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- (៨) ពង្រឹងនិងពង្រីកិច្ចសហប្រតិបត្តិការជាមួយ មន្ទីរ អង្គភាពនានាជុំវិញរាជធានី ខេត្ត និង
- (៩) គាំទ្រនិងអនុវត្តទិសដៅជាយុទ្ធសាស្ត្រនានារបស់ក្រសួង ស្ថាប័ននានា និងរាជរដ្ឋាភិបាល។

សូមអរគុណ

ចំពោះការយកចិត្តទុកដាក់ស្តាប់!!!